**M C S C**

**បេសកកម្ម ៖** ស្ថងការសាលារៀនឯករាជ្យសាធារណៈរដ្ឋមេន (Maine Charter School) នឹងជួយយ៉ាងហ្មត់ចត់ ក្នុងការផ្តល់សិទ្ធិ និងការត្រួតពិនិត្យសាលារៀនឯករាជ្យសាធារណៈ លើការដើរស្របផ្លូវគ្នាជាមួយនឹងលក្ខន្តិកៈរដ្ឋ ដើម្បីបង្កើតបាននូវជម្រើសការសិក្សាដែលមានលក្ខណៈពិសេស មានគុណភាពខ្ពស់ សម្រាប់សិស្សសាលារដ្ឋមេន ។

**មានចំនួនច្រើនជាង 2,000 នាក់ បានចុះឈ្មោះចូលរៀន**






**សិស្សចុះឈ្មោះចូលរៀនទាំងអស់ មកពីទីក្រុង និងនិគមន៍ ចំនួន 294 ទូទាំងរដ្ឋមេន**



## សាលារៀន 9

**គោលបំណង ៖** ដើម្បីផ្តល់ឲ្យសាលាឯករាជ្យសាធារណៈ អាចបង្កើតបានជាសាលារៀនសាធារណៈ ដែល ៖

- លើកកម្ពស់ការសិក្សារបស់សិស្ស ដោយការបង្កើតនូវសាលារៀនដែលកាន់តែមានគុណភាព ជាមួយនឹងបទដ្ឋានខ្ពស់ចំពោះការសិក្សារបស់សិស្ស
- បន្ថយគម្លាតរវាងក្រុមសិស្សដែលរៀនបានពិន្ទុខ្ពស់ និងសិស្សដែលរៀនបានពិន្ទុទាប នៅសាលារដ្ឋ
- បង្កើនឱកាសការអប់រំដែលមានគុណភាពខ្ពស់ នៅក្នុងប្រព័ន្ធសិក្សាធិការសាធារណៈ
- ផ្តល់បរិយាកាសការសិក្សារៀនសូត្រជាជម្រើស ចំពោះសិស្សដែលមិនចង់រៀនក្នុងថ្នាក់ រៀបចំបង្រៀនតាមបែបចាស់
- បង្កើតឱកាសវិជ្ជាជីវៈថ្មី សម្រាប់គ្រូ និងបុគ្គលិកដទៃទៀតរបស់សាលា
- លើកទឹកចិត្តឲ្យប្រើម៉ូដែលថ្មីៗ និងមានគុណភាពខ្ពស់ចំពោះការបង្រៀន និងទិដ្ឋភាពដទៃទៀតលើការសិក្សារៀនសូត្រ ព្រមទាំង
- ផ្តល់ដល់សិស្ស ឪពុកម្តាយសិស្ស សមាជិកសហគមន៍ និងអង្គភាពមូលដ្ឋាន នូវឱកាសទូលាយ ដើម្បីចូលរួមក្នុងប្រព័ន្ធសិក្សាធិការសាធារណៈ ។

182 State House Station
Augusta, ME 04333-0182

ទាក់ទងយើងខ្ញុំ!

mcsc@maine.gov
(207)624-6720

# ការយល់ខុសទូទៅអំពីសាលារៀនឯករាជ្យសាធារណៈ

**ការយល់ខុស ៖** គ្រូប្រចាំសាលារៀនឯករាជ្យសាធារណៈ មិនចាំបាច់មានអាជ្ញាប័ណ្ណឡើយ ។

**ភាពពិត ៖** សាលារៀនឯករាជ្យសាធារណៈ ត្រូវអនុវត្តតាមច្បាប់ និងបទបញ្ញត្តិសហព័ន្ធដែលពាក់ព័ន្ធនឹងគុណវុឌ្ឍិរបស់គ្រូ និងបុគ្គលិកសិក្សាផ្សេងទៀត ។ គ្រូបង្រៀនពេញម៉ោងទាំងអស់របស់សាលារៀនឯករាជ្យសាធារណៈ របស់រដ្ឋមេន ត្រូវមានសញ្ញាប័ត្រផ្នែកបង្រៀនត្រឹមត្រូវតាមការកំណត់ ឬក៏ទទួលបានការទទួលស្គាល់ផ្នែកការបង្រៀនក្នុងរវាង 3 ឆ្នាំ គិតចាប់ពីថ្ងៃចូលបង្រៀន លើកលែងចំពោះអ្នកដែលមានបរិញ្ញាប័ត្រជាន់ខ្ពស់ ដែលមានលិខិតបញ្ជាក់អំពីវិជ្ជាជីវៈរបស់ខ្លួន ឬ មានឯកទេសពិសេសចំពោះកម្មវិធីសិក្សាលើមុខវិជ្ជាដែលខ្លួនបង្រៀន ។

**ការយល់ខុស ៖** សាលារៀនឯករាជ្យសាធារណៈ មិនចាំបាច់ដើរតាមបទដ្ឋានសិក្សាធិការ ដូចសាលាឌីស្ទ្រិកឡើយ ។

**ភាពពិត ៖** សាលារៀនឯករាជ្យសាធារណៈ មានកាតព្វកិច្ចដើរតាមបទដ្ឋានសិក្សាធិកា និងបទដ្ឋានការសិក្សារបស់រដ្ឋមេន ដូចគ្នានឹងសាលាឌីស្ទ្រិកសាធារណៈទូទៅដែរ ។ លើសពីនេះ សាលារៀនទាំងនេះ ត្រូវដើរតាមវិធានការណ៍គណនេយ្យភាព ដែលមានចែងក្នុងកិច្ចសន្យារបស់ខ្លួនជាមួយនឹងអ្នកផ្តល់សិទ្ធិឲ្យបើកសាលារៀនទាំងនេះ ។

**ការយល់ខុស ៖** សាលារៀនឯករាជ្យសាធារណៈ ជាសាលាឯកជន ។

**ភាពពិត ៖** សាលារៀនឯករាជ្យសាធារណៈ ជាសាលារៀនរដ្ឋ ដែលជាផ្នែកមួយនៃប្រព័ន្ធសិក្សាធិការសាធារណៈ របស់រដ្ឋមេន ។

សាលារៀនឯករាជ្យសាធារណៈរដ្ឋមេន ៖

- ត្រូវតែមិនមែនជាសាលាប្រកាន់សាសនា
- ត្រូវតែមិនយកថ្លៃសាលាពីសិស្ស
- អាចមិនចាំបាច់ប្រឡងចូល
- ត្រូវតែទទួលសិស្សទាំងអស់ចូលរៀនដោយស្មើភាពគ្នា
- ដើម្បីធានាបានស្ថានភាពស្មើភាពគ្នាក្នុងការទទួលសិស្សឲ្យចូលរៀន ក្នុងករណីមានសិស្សច្រើនហួសកំណត់ដាក់ពាក្យចូលរៀន ត្រូវធ្វើការចាប់ឆ្នោត ។




**ការយល់ខុស ៖** សាលារៀនឯករាជ្យសាធារណៈ ជាសាលារៀនសម្រាប់សិស្សចូលចិត្ត “បង្ករបញ្ហា” ។

**ភាពពិត ៖** សាលារៀនឯករាជ្យសាធារណៈ គឺជាសាលារៀនសម្រាប់សិស្សទូទៅ ។ សាលារៀនឯករាជ្យសាធារណៈ មានភាពចម្រុះចំពោះបេសកកម្ម កម្មវិធី និងក្រុមគោលដៅរបស់ខ្លួន ។

**ការយល់ខុស ៖** សាលារៀនឯករាជ្យសាធារណៈ មិនមានផ្តល់សេវាកម្មអប់រំពិសេសឡើយ ។

**ភាពពិត ៖** សាលារៀនឯករាជ្យសាធារណៈ ត្រូវផ្តល់សេវាកម្មអប់រំពិសេសដល់សិស្ស ដោយអនុលោមទៅតាមភាពតម្រូវពីសហព័ន្ធ និងរដ្ឋ ដូចគ្នានឹងអ្វីដែលសាលាឌីស្ទ្រិក ត្រូវធ្វើផងដែរ ។

**ការយល់ខុស ៖** សាលារៀនឯករាជ្យសាធារណៈ ជាសាលា “លួចប្រាក់” ពីប្រព័ន្ធសាលារៀនសាធារណៈ ។

**ភាពពិត ៖** ដោយសារថាសាលារៀនឯករាជ្យសាធារណៈ ជាសាលារៀនសាធារណៈ ប្រាក់សម្រាប់ឧបត្ថម្ភដល់សិស្សដែលសម្រេចចិត្តចូលរៀនក្នុងសាលារៀននេះ គឺនៅតែស្ថិតក្នុងប្រព័ន្ធសិក្សាធិការសាធារណៈ ។

**ការយល់ខុស ៖** សាលារៀនឯករាជ្យសាធារណៈ ទទួលបានថវិកាឧបត្ថម្ភពីរដ្ឋ ច្រើនជាងសាលារៀនឌីស្ទ្រិកទូទៅ ។

**ភាពពិត ៖** ថវិការដ្ឋសម្រាប់ឧបត្ថម្ភដល់សិស្សម្នាក់ៗ គឺនឹងបែងចែកសម្រាប់សិស្សម្នាក់ៗទៅតាមសាលារៀនឌីស្ទ្រិក ឬសាលារៀនឯករាជ្យសាធារណៈ គឺគណនាដោយប្រើរូបមន្ត “កម្មវិធីការបែងចែកប្រាក់ជំនួយ-Essential Program Allocation” (EPA) ដូចៗគ្នាទាំងអស់ ។ សាលារៀនឌីស្ទ្រិក ទទួលបានថវិការដ្ឋច្រើនជាង សម្រាប់ជាសោធននិវត្តន៍ដល់គ្រូ សម្រាប់ការសាងសង់ និងជួសជុលអាគារសិក្សា និងសម្រាប់ការចំណាយនានា ដូចជាការចំណាយលើរថយន្តសាលារៀនជាដើម ។ សាលាឌីស្ទ្រិកភាគច្រើនក៏ទទួលបានថវិកាមូលដ្ឋានតាមរយៈ “ការផ្តល់ប្រាក់ឧបត្ថម្ភបង្គ្រប់” ។ សាលារៀនឯករាជ្យសាធារណៈ អាចមិនប្រមូលពន្ធលើអចលនទ្រព្យ ដែលជាប្រភពចំណូលបន្ថែមរបស់សាលាឌីស្ទ្រិក ។

**ការយល់ខុស ៖** សាលារៀនឯករាជ្យសាធារណៈ ទទួលយកតែសិស្សពូកែចូលរៀន ។

**ភាពពិត ៖** សាលារៀនឯករាជ្យសាធារណៈ បើកទទួលសិស្សទូទៅ ហើយសិស្សអាចមិនបាច់ប្រឡងចូលឡើយ ។ សាលារៀនឯករាជ្យសាធារណៈ មិនគិតលើមូលដ្ឋានប្រាជ្ញា ការវាស់វែងកម្រិតការសិក្សា ឬភាពវ័យឆ្លាត ឬសមត្ថភាពរាងកាយ ជាដែនកំណត់ក្នុងការទទួលសិស្សចូលរៀនឡើយ ។

© MCSC 2018